| ១០-លោក **ទេព គីឡា** | តំណាងបុគ្គលិកមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល | សមាជិកស្វ័យប្រវត្តិ។ |

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..៥២៦...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

**សម្រេច**

**មាត្រា ១.-**

បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ចំនួន ០១គ្រឿង ជូនលោក **នៃ សុធា** សប្បុរសជននៅរាជធានីភ្នំពេញ ដែលបានបរិច្ចាគ ធនធានផ្ទាល់ខ្លួនចូលរួមជួយកសាង សាលាពុទ្ធិកបឋមសិក្សានៅវត្តមហានិគ្រោធ (ហៅវត្តព្រែកដំបងចាស់) ស្ថិតនៅក្នុងឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៤១ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកណ្តាល

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ១២គ្រឿង ជូនសប្បុរសជននៅក្នុងនិងក្រៅប្រទេស ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាង សាលាពុទ្ធិកបឋមសិក្សានៅវត្តមហានិគ្រោធ (វត្តព្រែកដំបងចាស់) ស្ថិតនៅក្នុងឃុំព្រែកដំបង ស្រុកមុខកំពូល ខេត្តកណ្តាល កន្លងមក សម្រេចបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | ឧបាសិកា | សាន់ សុផាត | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក |
| ២- | លោក | អ៊ិន ហន | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៣- | អ្នកស្រី | អ៊ិត លក្ខិណា | សប្បុរសជននៅរាជធានីភ្នំពេញ |
| ៤- | អ្នកស្រី | អ៊ុំ មុន្នីរ៉េម | សប្បុរសជននៅឃុំព្រែកដំបង |
| ៥- | ឧបាសក | ម៉ក់ ថុន | សប្បុរសជននៅឃុំព្រែកដំបង |
| ៦- | លោក | អ៊ុំ ប៊ុំ | សប្បុរសជននៅឃុំព្រែកដំបង |
| ៧- | លោក | ម៉ែន ហ៊ុន | សប្បុរសជននៅឃុំព្រែកដំបង |
| ៨- | លោក | យស ស៊ីផាន | សប្បុរសជននៅឃុំព្រែកដំបង |
| ៩- | អ្នកស្រី | គង់ ឡាង | សប្បុរសជននៅរាជធានីភ្នំពេញ |
| ១០- | ឧបាសិកា | គុជ ស្រីកែវ | សប្បុរសជននៅរាជធានីភ្នំពេញ |
| ១១- | ឧបាសិកា | គីម ហានុ | សប្បុរសជននៅរាជធានីភ្នំពេញ |
| ១២- | ឧបាសិកា | ឈុំ ឡា | សប្បុរសជននៅរាជធានីភ្នំពេញ |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តកណ្តាល និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥២៤ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា ១.**- បំពាក់ មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ **ធិបឌិន្ទ** ចំនួន ២០គ្រឿង ជូនសាសនិកឥស្លាម ចំនួន ២០រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងថវិកា ក្នុងការជួយកសាង វិហារឥស្លាម (ម៉ាស្ជិត) ភូមិឃ្លាំងស្បែក ភូមិទួលងោក ស្ថិតនៅក្នុងឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- | លោក | **ពាស់** | **ឯល** | ប្រធានសមាគមកីឡា ភូមិឃ្លាំងស្បែក |
| ២- | លោក | **រូន** | **សារីម** | ប្រធានសមាគមសព ភូមិឃ្លាំងស្បែក |
| ៣- | លោក | **ហាប់** | **ស្លែម៉ាន** | អនុប្រធានសមាគមសព ភូមិឃ្លាំងស្បែក |
| ៤- | លោក | **ឯល** | **មហាម៉ាត់សារី** | ពូឈ្មយ អ៊ីម៉ាំម៉ាស្ជិត ភូមិឃ្លាំងស្បែក |
| ៥- | ព្រឹទ្ធាចារ្យ | **សុះ** | **ម៉ាត់** | ភូមិឃ្លាំងស្បែក |
| ៦- | ព្រឹទ្ធាចារ្យ | **សើ** | **សារី** | ភូមិឃ្លាំងស្បែក |
| ៧- | ព្រឹទ្ធាចារ្យ | **ហ៊ីម** | **តាស់** | ភូមិឃ្លាំងស្បែក |
| ៨- | ព្រឹទ្ធាចារ្យ | **ហ៊ីម** | **ឡោះ** | ភូមិឃ្លាំងស្បែក |
| ៩- | ព្រឹទ្ធាចារ្យ | **ស្លាស់** | **លី** | ភូមិឃ្លាំងស្បែក |
| ១០- | លោក | **ប្រាក់** | **សើហ្វី** | សមាជិក |
| ១១- | លោក | **ហៃ** | **យើ** | សមាជិក |
| ១២- | លោក | **សើ** | **សាឡេះ** | សមាជិក |
| ១៣- | លោក | **ម៉ាត់** | **ស្លាឯល** | សមាជិក |
| ១៤- | លោក | **នាក់** | **យើ** | សមាជិក |

| | | | | |
|---|---|---|---|---|
| ១៥- | លោក | ឡុង | ម៉ាត់លី | សមាជិក |
| ១៦- | លោក | ម៉ាត់ | រ៉ូសាលី | សមាជិក |
| ១៧- | លោក | យូ | ស៊ុះអាប់ឌុលសាម៉ាត់ | សមាជិក |
| ១៨- | លោក | ឯល | សាទី | សមាជិក |
| ១៩- | លោក | សាឡេះ | យ៉ាក់កូប | សមាជិក |
| ២០- | លោក | យូ | សិបពីអ៊ី | សមាជិក |

**មាត្រា ២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរវជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥២៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **អ៊ុំ ចណ្ណា** ឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ៧ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអភិបាលរង នៃគណៈអភិបាលខេត្តព្រៃវែង ។

**មាត្រា ២ :** ក្នុងរយៈពេលមកបំពេញភារកិច្ចក្នុងមុខតំណែងខាងលើនេះ លោក **អ៊ុំ ចណ្ណា** ត្រូវដាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៣០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
-បានឃើញអនុក្រឹត្យ លេខ ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
-បានឃើញអនុក្រឹត្យ លេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ
-បានឃើញអនុក្រឹត្យ លេខ ១៧៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **ជុំ ផល្លា** អត្តលេខ ៧៣៣៦៣ ពីប្រធានលេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមាននៅក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៣១ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយសហមេត្រី

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

**សម្រេច**

**មាត្រា១.** បំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូននាយទាហាននៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន១១រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរព័ត៌មានចារកម្មរវាងប្រទេសទាំងពីរ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | **ឡឿង** | **វ៉ាន់ហាន់** | ប្រធានមុខវិជ្ជាសាខាវិទ្យាស្ថាន វិទ្យាសាស្ត្រយោធា |
| ២-វរសេនីយ៍ឯក | **ឡេ** | **ឌុកជិន** | ប្រធានមុខវិជ្ជាសាខាវិទ្យាស្ថាន វិទ្យាសាស្ត្រយោធា |
| ៣-វរសេនីយ៍ឯក | **ឡេ** | **វ៉ាន់ហឺង** | គ្រូបង្រៀន សាខាវិទ្យាស្ថាន វិទ្យាសាស្ត្រយោធា |
| ៤-វរសេនីយ៍ឯក | **ឡឿន** | **វ៉ាន់ថាន់** | គ្រូបង្រៀន សាខាវិទ្យាស្ថាន វិទ្យាសាស្ត្រយោធា |
| ៥-វរសេនីយ៍ឯក | **ឡេ** | **វ៉ាន់ហ៊្វា** | គ្រូបង្រៀន សាខាវិទ្យាស្ថាន វិទ្យាសាស្ត្រយោធា |
| ៦-វរសេនីយ៍ឯកបំរុង | **វូ** | **ឌឹកធិន** | ស្នងការទី១២ |
| ៧-វរសេនីយ៍ឯកបំរុង | **ឡឿង** | **ថាន់បេ** | ស្នងការទី១២ |
| ៨-វរសេនីយ៍ទោ | **ផាម** | **វ៉ាន់ត្រឹក** | ស្នងការទី១២ |
| ៩-វរសេនីយ៍ទោ | **ឡេ** | **ហ្វាងយ៉ុង** | ស្នងការទី១២ |
| ១០-វរសេនីយ៍ទោ | **ហា** | **ស៊ុនថាន** | ស្នងការទី១២ |
| ១១-វរសេនីយ៍ទោ | **ឈឿន** | **ឌិនមិញ** | ស្នងការទី១២ |

**មាត្រា២.** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:**..៥៣៧..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណ:រដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

## សម្រេច

**មាត្រា១.**.បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៦រូប ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការចលនាពុទ្ធបរិស័ទ និងបរិច្ចាគថវិកាចូលរួមជួយកសាងសមិទ្ធផលវិស័យព្រះពុទ្ធសាសនា នៅវត្តរតនារាម (វត្តផ្សារកណ្តាល) ភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

-ព្រះភិក្ខុបាសធម្មោ ម៉ូច ពឿន ចៅអធិការវត្តរតនារាម (វត្តផ្សារកណ្តាល)

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | | | |
|---|---|---|---|---|
| ១-ព្រះភិក្ខុ **ឃុត** | **ឃន** | គង់នៅវត្តរតនារាម (វត្តផ្សារកណ្តាល) | | |
| ២-លោក **ពិន** | **សាវឿត** | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ៣០.០០០ ដុល្លារ |
| ៣-លោក **ឌិុច** | **អេងថុង** | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ២៩.២០០ ដុល្លារ |
| ៤-អ្នកស្រី **ជាច** | **ណារី** | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ២៩.២៥០ ដុល្លារ |
| ៥-លោក **ស៊ុន** | **សាធុច** | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ២៩.១៤៨ ដុល្លារ |

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណ:រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណ:អភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០១៤
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:៥៣៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា

**សម្រេច**

**មាត្រា១.** បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន២៣រូប ដែលបានបរិច្ចាគថវិកាចូលរួមជួយកសាងសមិទ្ធផលវិស័យព្រះពុទ្ធសាសនា នៅវត្តរតនារាម (វត្តផ្សារកណ្តាល) ភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| ១-លោក | សុខ | ខឿន | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ២-លោក | តេម | សុជាតិ | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៣-លោក | គាត | ហ៊ុល | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤-លោក | ខាត់ | ម៉េង | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៥-លោក | ឡាយ | អ៊ុយ | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៦-លោក | យឹម | ថៃហួរ | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៧-លោក | លី | សៀវផេង | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ១០.០០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| ១-លោក | យឹម | ពិសិដ្ឋ | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ២-លោក | ធិត្យ | ចន្ទរាលី | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៣-អ្នកស្រី | ញូង | នុច | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៤-លោក | ខ្លែង | សុឃឺ | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៥-អ្នកស្រី | ឆោ | វណ្ណានី | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៦-លោក | ហូ | គឹមឡេង | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ៥.០០០ ដុល្លារ |
| ៧-លោក | ថាន | ថេន | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន ៥.០០០ ដុល្លារ |

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ**

| | | | | | |
|---|---|---|---|---|---|
| ១-លោក | គឹម | គៅ | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ១.១០០ ដុល្លារ |
| ២-លោក | សុខ | ម៉ៅ | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ១.១៥០ ដុល្លារ |
| ៣-លោក | អ៊ូ | វីណា | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ១.០៥០ ដុល្លារ |
| ៤-លោក | សែម | តារា | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៥-លោក | អេង | លីហួ | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៦-លោក | ម៉ែន | ទិន | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៧-អ្នកស្រី | ហេង | ទ៉ារិន | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៨-អ្នកស្រី | ឡៀង | អេង | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៩-លោក | គីត | ផា | សប្បុរសជនក្រុងប៉ោយប៉ែត | ថវិកាចំនួន | ១.០០០ ដុល្លារ |

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៣៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា១.**_បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៣រូប ដែលបានខិតខំប្រឹងប្រែង អស់ពីកម្លាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកជួយកសាងសមិទ្ធផលនានាជាច្រើនលើវិស័យព្រះពុទ្ធសាសនា ស្ថិតនៅវត្តមង្គលរតនារាម ភូមិអូរវ៉ាបុង ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

| | | |
|---|---|---|
| ១-ព្រះភិក្ខុ | **គីន សុគី** | ព្រះចៅអធិការវត្តមង្គលរតនារាម បានខិតខំចលនាពុទ្ធបរិស័ទយ៉ាងសកម្មក្នុងការកសាងវត្ត និងជាមេជាងផ្ទាល់ |
| ២-លោកស្រី | **ពេជ្រ ប៊ុនធិនបុប្ផាច័ន្ទ** | អត្តលេខ ០៥១១៣ មន្ត្រីនគរបាល |

**ខ-មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

| | | |
|---|---|---|
| -លោក | **ស៊ិន ធុន** | គណៈកម្មការវត្ត |

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលខេត្តក្រចេះ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៣៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា១.**-បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០២រូប ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកជួយកសាងសមិទ្ធផលនានាជាច្រើន លើវិស័យព្រះពុទ្ធសាសនា ស្ថិតនៅវត្តមង្គលរតនារាម ភូមិអូរលុង ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ**

-លោក **យ៉ែម សុផល** សប្បុរសជន ថវិកាចំនួន ១១.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

-លោក **ហាក់ ហៀប** សប្បុរសជន ថវិកាចំនួន ៤.៥០០ ដុល្លារ

**មាត្រា២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ អភិបាលនៃគណៈអភិបាលខេត្តក្រចេះ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**...៥៣៦...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ៩៤៨ អនក្រ.តត ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល អគ្គិសនីកម្ពុជា អាណត្តិទី៦

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអគ្គិសនីកម្ពុជា ជាក្រុមហ៊ុនទទួលខុសត្រូវមានកំណត់មួយរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

## សម្រេច

**មាត្រាមួយ.-**

មាត្រា១ នៃ អនុក្រឹត្យលេខ ៩៤៨ អនក្រ.តត ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា អាណត្តិទី៦ ត្រូវបានធ្វើការកែសម្រួលដូចតទៅៈ

**មាត្រា១.-ថ្មី**

ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា អាណត្តិទី៦ ដូចមានរាយនាមខាងក្រោមៈ

| | |
|---|---|
| ១- ឯកឧត្តម **កែវ រតនៈ** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក អគ្គិសនីកម្ពុជា |
| ២- ឯកឧត្តម **ហែម ក្រាញ់តូនី** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិក ក្រុមប្រឹក្សាអ្នកច្បាប់ |
| ៣- ឯកឧត្តម **ចាន់ សុធី** | អគ្គលេខាធិការរង នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៤- ឯកឧត្តម **វិចទ័រ ហ្យូនា** | អគ្គនាយក នៃអគ្គនាយកដ្ឋានថាមពល ក្រសួងរ៉ែនិងថាមពល |
| ៥- លោក **គី ខេមលីម** | អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍ លើវិស័យយុត្តិធម៌ នៃក្រសួងយុត្តិធម៌ |
| ៦- លោកស្រី **សុខ សុទ្ធាវី** | ប្រធានរដ្ឋបាលសភាពាណិជ្ជកម្មកម្ពុជា |
| ៧- លោក **ហាន់ ទូច** | តំណាងនិយោជិតកម្មករអគ្គិសនីកម្ពុជា |

**មាត្រាពីរ.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា ១:** ប្រគល់ភារកិច្ចជូនលោកវេជ្ជបណ្ឌិត **សុខ ស្រ៊ុន** ជាប្រធាននាយកដ្ឋានមន្ទីរពេទ្យ នៃក្រសួងសុខាភិបាល។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែឧសភា ឆ្នាំ ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៥៣៧...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៩រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងផ្លូវបេតុង ចំនួន០២ខ្សែ និងផ្លូវក្រាលគ្រួសក្រហម ចំនួន០១ខ្សែ ស្ថិតនៅក្នុងសង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **សាខ** | **សុភា** | គង់នៅខេត្តសៀមរាប | បច្ច័យចំនួន ១០.០០០ ដុល្លារ |
| ២-ឧបាសក | **រិត** | **ឆ្មុយ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.២០០ ដុល្លារ |
| ៣-លោកអាចារ្យឈុប | **វ៉ាត់** | | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៤-អ្នកស្រី | **ហុក** | **ភ្លឺខ** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៥-លោក | **លឹម** | **ឌីណា** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៦-លោក | **ជា** | **ចំរើន** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៧-លោក | **ទៀម** | **ចាន់បូណា** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៨-អ្នកស្រី | **ហ៊ឹម** | **សុគុល** | សប្បុរសជននៅខេត្តសៀមរាប | ថវិកាចំនួន ១០.០០០ ដុល្លារ |

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| -លោក | **ឡិ** | **ពៅ** | សប្បុរសជននៅខេត្តយសៀមរាប | ថវិកាចំនួន ៣.០០០ ដុល្លារ |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៣៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**មាត្រា ១.-** បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន២១រូប ដែលបានជួយកសាងវត្តវេឡុវនារាម ហៅ វត្តធុតង្គ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | **តូច** | **ផុន** | ក្រុមប្រឹក្សាឃុំ |
| ២-លោកស្រី | **អុង** | **ស៊ីមអ៊ីន** | ក្រុមប្រឹក្សាឃុំ |
| ៣-លោក | **ម៉ិល** | **សម្ផស** | ស្មៀនឃុំ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-ព្រឹទ្ធាចារ្យ | **យ៉ង** | **ណែម** | សប្បុរសជន |
| ២-ឧបាសិកា | **ង៉ូច** | **សុខរ៉ុង** | សប្បុរសជន |
| ៣-ឧបាសិកា | **គីម** | **ឡាង** | សប្បុរសជន |
| ៤-ឧបាសិកា | **កែវ** | **គង់** | សប្បុរសជន |
| ៥-លោក | **ងី** | **អ៊ាប** | សប្បុរសជន |
| ៦-លោក | **លី** | **ងីន** | សប្បុរសជន |
| ៧-លោក | **ឡឹក** | **យាត** | អាចារ្យវត្ត |
| ៨-លោក | **កែវ** | **សាន** | អាចារ្យវត្ត |
| ៩-លោក | **សោ** | **ផុន** | អាចារ្យវត្ត |
| ១០-លោក | **អុំ** | **ទ្រា** | អាចារ្យវត្ត |

**គ-មេជាយសំរែទ្ធស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១-លោក | ឃៀង | មិន | គណៈកម្មការវត្ត |
| ២-លោក | កែ | សុខ | គណៈកម្មការវត្ត |
| ៣-លោក | ឌួច | ធីម | គណៈកម្មការវត្ត |
| ៤-លោក | អ៊ី | អ៊ាន | គណៈកម្មការវត្ត |
| ៥-លោក | ទ៊ុន | ទ៉ាត | គណៈកម្មការវត្ត |
| ៦-លោក | ឃុន | ពត | គណៈកម្មការវត្ត |
| ៧-អ្នកស្រី | ឈុំ | ម៉ៅ | គណៈកម្មការវត្ត |
| ៨-លោក | ថៅ | ផេង | មេភូមិ |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៦១៦ សហវ.ប្រក

**ប្រកាស**

**ស្តីពី**

**ការកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្តល់ការលើកទឹកចិត្ត ដោយប្រើប្រាស់ប្រាក់ចំណូលរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ១.-**

ប្រកាសនេះមានគោលដៅកំណត់គោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យសម្រាប់ការផ្ដល់ការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រកបដោយសមធម៌ ស័ក្តិសិទ្ធភាព ប្រសិទ្ធភាព សង្គតិភាព តម្លាភាព និងគណនេយ្យភាព ដោយប្រើប្រាស់ប្រាក់រង្វាន់របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលត្រូវបានសម្រេចផ្ដល់ជូនដោយរាជរដ្ឋាភិបាល។

**ប្រការ២.-**

ប្រកាសនេះមានគោលបំណងជាសារវន្តដូចខាងក្រោម៖

- ពង្រឹងនិងបង្កើនផលិតភាព គុណភាព ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃសមិទ្ធកម្មរបស់មន្ត្រីរាជការរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ផ្ដល់ការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក និងអង្គភាព ដោយផ្អែកលើសមិទ្ធកម្ម និងអនុលោមតាមគោលការណ៍គុណាធិបតេយ្យ ប្រកបដោយសមធម៌ សង្គតិភាព តម្លាភាព និងគណនេយ្យភាព
- ធានាសុខដុមនីយកម្មនៃគោលការណ៍ យន្តការ នីតិវិធី និងការត្រួតពិនិត្យនៃការផ្ដល់ការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក និងអង្គភាពដោយប្រើប្រាស់ប្រាក់រង្វាន់នៅក្នុងក្របខ័ណ្ឌនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រួមចំណែកទ្រទ្រង់ការអនុវត្តគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះ ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងគ្រប់អង្គភាពដែលបម្រើការងារនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២
## គោលការណ៍លើកទឹកចិត្ត

**ប្រការ៤.-**

ការលើកទឹកចិត្តគឺជាការផ្តល់ប្រាក់ឧបត្ថម្ភ ប្រាក់រង្វាន់ ឬមូលនិធិនានាបន្ថែមលើបៀវត្សរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកដែលបានបំពេញមុខងារនិងភារកិច្ចរបស់ខ្លួនប្រកបដោយផលិតភាព គុណភាព ស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងគណនេយ្យភាព តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៥.-**

ការលើកទឹកចិត្ត ត្រូវផ្តល់ជូនចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិក ឬអង្គភាព តាម ៤ ប្រភេទគឺ ***ប្រាក់ឧបត្ថម្ភជីវភាព ប្រាក់ឧបត្ថម្ភមុខងារ ប្រាក់រង្វាន់សមិទ្ធកម្ម*** និង***មូលនិធិអភិវឌ្ឍស្ថាប័ន***។ ការលើកទឹកចិត្តនៃប្រភេទនីមួយៗត្រូវផ្តល់តាមគោលការណ៍ដូចខាងក្រោម÷

- **ប្រាក់ឧបត្ថម្ភជីវភាព** ត្រូវផ្តល់ជូនមន្ត្រីរាជការនិងបុគ្គលិកទាំងឡាយណា ដែលមកបំពេញការងារទៀងទាត់ តាមមុខងារប្រកបដោយគុណភាព និងផលិតភាព។
- **ប្រាក់ឧបត្ថម្ភមុខងារ** ត្រូវផ្តល់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកទាំងឡាយណាដែលបំពេញមុខងារពាក់ព័ន្ធនឹងការងារដឹកនាំ ការងារកែទម្រង់ ការងារសិក្សាស្រាវជ្រាវ ការងាររៀបចំច្បាប់និងគោលនយោបាយ ការងារជំនាញចាំបាច់ ការងារចូលរួមអនុវត្តគម្រោង និងក្រុមការងារផ្សេងៗ ព្រមទាំង ការងារផ្តល់មតិប្រឹក្សាច្បាប់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- **ប្រាក់រង្វាន់សមិទ្ធកម្ម** ត្រូវផ្តល់ជូនមន្ត្រីរាជការ បុគ្គលិក ឬអង្គភាព ដែលសម្រេចបានលទ្ធផលលើសគោលដៅកំណត់ ដូចជាការប្រមូលចំណូលបានលើសគោលដៅកំណត់ ការបង្កើតឱ្យមានផលចំណេញថវិកា ការសម្រេចលទ្ធផលការងារបានមុនផែនការកំណត់ ការសន្សំសំចៃថវិកាបានដោយចំណាយតិចជាងគោលការណ៍កំណត់។ល។
- **មូលនិធិអភិវឌ្ឍស្ថាប័ន** ត្រូវផ្តល់ជូនអង្គភាពដែលមានតម្រូវការចាំបាច់ មានផែនការអភិវឌ្ឍស្ថាប័នដែលរួមទាំងផែនការអភិវឌ្ឍធនធានមនុស្សប្រចាំឆ្នាំច្បាស់លាស់ និងដែលឆ្លើយតបពិតប្រាកដទៅនឹងសេចក្តីត្រូវការចាំបាច់នៃមុខងារក្នុងការអនុវត្តកម្មវិធី និងគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងទៅតាមលទ្ធភាពជាក់ស្តែងនៃមូលនិធិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៦.-**

ការលើកទឹកចិត្តត្រូវផ្តល់ទៅតាមសន្ទស្សន៍ តម្លៃឯកតានៃសន្ទស្សន៍ ភាគរយ និងលទ្ធភាពដែលត្រូវបានកំណត់ទៅតាមប្រភេទទាំង ៤ ដូចខាងក្រោម÷

**ក- ប្រាក់ឧបត្ថម្ភជីវភាព** ត្រូវផ្តល់ប្រចាំខែ និងត្រូវបានកំណត់ជាសន្ទស្សន៍ដូចខាងក្រោម÷

១- អគ្គលេខាធិការ/អគ្គនាយក អគ្គលេខាធិការរង/អគ្គនាយករង និងអគ្គាធិការ/អគាធិការរង មានសន្ទស្សន៍ស្មើនឹង ២៥

២- ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន មានសន្ទស្សន៍ស្មើនឹង ៣០

៣- ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ មានសន្ទស្សន៍ស្មើនឹង ៧៥

៤- មន្ត្រី ទីប្រឹក្សា និងជំនួយការ មានសន្ទស្សន៍ស្មើនឹង ១០០។

**ខ- ប្រាក់ឧបត្ថម្ភមុខងារ** ត្រូវផ្តល់ប្រចាំខែ និងត្រូវបានកំណត់ជាសន្ទស្សន៍ដូចខាងក្រោម÷

១- រដ្ឋមន្ត្រី មានសន្ទស្សន៍ស្មើនឹង ២១០៥

២- រដ្ឋលេខាធិការ មានសន្ទស្សន៍ស្មើនឹង ១៣១៦

៣- អនុរដ្ឋលេខាធិការ មានសន្ទស្សន៍ស្មើនឹង ១០៥៣

៤- ប្រធានគម្រោង មានសន្ទស្សន៍ស្មើនឹង ៥២៦

៥- អនុប្រធានគម្រោង មានសន្ទស្សន៍ស្មើនឹង ៣៩៥

៦- ប្រធានក្រុមការងារ មានសន្ទស្សន៍ស្មើនឹង ៣៤២

៧- មន្ត្រីជំនាញជាន់ខ្ពស់ មានសន្ទស្សន៍ស្មើនឹង ២៦៣

៨- មន្ត្រីជំនាញ មានសន្ទស្សន៍ស្មើនឹង ២១១។

គម្រោងត្រូវមានទំហំការងារ ដែលត្រូវអនុវត្តក្នុងរយៈពេលចាប់ពីមួយឆ្នាំឡើងទៅ។ សម្រាប់ទំហំការងារដែលត្រូវអនុវត្តក្នុងរយៈពេលតិចជាងមួយឆ្នាំ ត្រូវបង្កើតត្រឹមតែកម្រិតនៃក្រុមការងារ។ សម្រាប់ទំហំការងារដែលត្រូវអនុវត្តក្នុងរយៈពេលតិចជាង ៣ខែ ត្រូវអនុវត្តក្នុងក្របខ័ណ្ឌការងារប្រចាំថ្ងៃធម្មតា។

ថ្នាក់ដឹកនាំ មន្ត្រីរាជការ ឬបុគ្គលិកម្នាក់ៗអាចចូលរួមអនុវត្តការងារក្នុងគម្រោង ឬក្រុមការងារលើសពីមួយបាន គិតទាំងគម្រោងជាមួយដៃគូអភិវឌ្ឍ គម្រោងមូលនិធិផ្សេងៗ និងសមាជិកភាពនៃក្រុមប្រឹក្សាភិបាលនៃសហគ្រាសសាធារណៈនិងគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬមន្ត្រីត្រួតពិនិត្យរដ្ឋ ប៉ុន្តែអនុញ្ញាតឱ្យមទួលប្រាក់ឧបត្ថម្ភមុខងារបានតែមួយប៉ុណ្ណោះ។

ក្នុងករណីមានជំនាញពិសេសចាំបាច់ ដែលជាក់ស្តែងតម្រូវឱ្យមានការផ្តល់ប្រាក់ឧបត្ថម្ភមុខងារខ្ពស់ គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត អាចពិនិត្យនិងសម្រេចលើសំណើផ្តល់តាមសន្ទស្សន៍ណាមួយក្នុងចំណោមសន្ទស្សន៍ទាំង ៨ ដែលបានកំណត់ខាងលើ។

**គ- ប្រាក់រង្វាន់សមិទ្ធកម្ម** ត្រូវផ្តល់ប្រចាំត្រីមាស ឬឆមាស ឬឆ្នាំ ទៅតាមពេលវេលាជាក់ស្តែងដែលបានកំណត់សម្រាប់ការវាស់វែងសមិទ្ធកម្ម និងត្រូវបានកំណត់ដោយផ្អែកលើការសម្រេចលទ្ធផលការងារលើសគោលដៅដូចតទៅ៖

***១- ករណីចំណូល*** ដែលបានប្រមូលលើសគោលដៅកំណត់ រង្វាន់សមិទ្ធកម្មត្រូវផ្តល់ជូនជាភាគរយនៃប្រាក់ចំណូលដែលលើសដល់សាមីអង្គភាព ឬក្រុមការងារ ដែលបានអនុវត្តការប្រមូលចំណូលនោះផ្ទាល់។ ចំណូលដែលជាកម្មវត្ថុសម្រាប់ការផ្តល់រង្វាន់សមិទ្ធកម្ម គឺជាចំណូលសរុបរបស់អង្គភាពអនុវត្តផ្ទាល់នីមួយៗ ធៀបនឹងគោលដៅដែលបានកំណត់នៅក្នុងផ្ទៃក្នុងអគ្គនាយកដ្ឋាន គឺមិនមែនចំណូលសរុបរបស់អគ្គនាយកដ្ឋានធៀបនឹងច្បាប់ប្រចាំឆ្នាំ ឬ/និងប្រភេទចំណូលថ្មីដែលរាជរដ្ឋាភិបាលបានដាក់ចេញនោះទេ។ ប្រាក់រង្វាន់សមិទ្ធកម្មនេះត្រូវផ្តល់ជូនប្រចាំឆ្នាំ និងត្រូវគិតជាភាគរយនៃប្រាក់ចំណូលលើសគោលដៅតាមអត្រាដូចខាងក្រោម៖

- ៥០ភាគរយ ក្នុងករណីចំណូលលើសមានចំនួនក្រោម ២០០ ០០០ ០០០ (ពីររយលាន) រៀល
- ៣០ភាគរយ ក្នុងករណីចំណូលលើសមានចំនួនចាប់ពី ២០០ ០០០ ០០០ (ពីររយលាន) រៀល រហូតដល់ក្រោម ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល
- ២០ភាគរយ ក្នុងករណីចំណូលលើសមានចំនួនចាប់ពី ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល រហូតដល់ក្រោម ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល
- ១៥ភាគរយ ក្នុងករណីចំណូលលើសមានចំនួនចាប់ពី ១ ០០០ ០០០ ០០០ (មួយពាន់លាន) រៀល រហូតដល់ក្រោម ២ ០០០ ០០០ ០០០ (ពីរពាន់លាន) រៀល
- ១០ភាគរយ ក្នុងករណីចំណូលលើសមានចំនួនចាប់ពី ២ ០០០ ០០០ ០០០ (ពីរពាន់លាន) រៀល រហូតដល់ក្រោម ៤ ០០០ ០០០ ០០០ (បួនពាន់លាន) រៀល
- ៥ភាគរយ ក្នុងករណីចំណូលលើសមានចំនួនចាប់ពី ៤ ០០០ ០០០ ០០០ (បួនពាន់លាន) រៀល ឡើងទៅ។

***២- ករណីចំណាយ*** ដែលត្រូវបានអនុវត្តដោយភាពសន្សំសំចៃ និងនៅសល់ពីកម្រិតចំណាយដែលបានគ្រោង និងផ្តល់តាមគោលការណ៍កំណត់ដោយសម្រេចបានលទ្ធផលការងារតាមការរំពឹងទុក រង្វាន់សមិទ្ធកម្មត្រូវផ្តល់ជូនក្នុងអត្រា ៥០% នៃចំនួនទឹកប្រាក់ដែលនៅសល់ ដល់សាមីអង្គភាព គម្រោង ឬក្រុមការងារ ដែលបានអនុវត្តការចំណាយនោះដោយផ្ទាល់។ ចំណាយដែលជាកម្មវត្ថុនៃការផ្តល់រង្វាន់សមិទ្ធកម្មគឺជាចំណាយតាមមុខសញ្ញានីមួយៗដែលបានគ្រោង និងផ្តល់តាមគោលការណ៍កំណត់ និង

ដែលមានសូចនាករ និងគោលដៅសម្រាប់វាស់លទ្ធផលច្បាស់លាស់ គឺមិនមែនចំណាយសរុបរបស់អង្គភាពនោះទេ។

*៣- ករណីផែនការការងារ* ដែលត្រូវបានអនុវត្តនិងសម្រេចបានមុនកាលកំណត់ រង្វាន់សមិទ្ធកម្មត្រូវផ្តល់ជូនតាមអត្រានៃប្រាក់ឧបត្ថម្ភមុខងារសម្រាប់រយៈពេលដែលនៅសល់ដល់សាមីអង្គភាព គម្រោង ឬក្រុមការងារដែលបានសម្រេចផែនការការងារមុនកាលកំណត់ដោយផ្ទាល់។

**ឃ- មូលនិធិអភិវឌ្ឍស្ថាប័ន** ត្រូវផ្តល់ដល់អង្គភាពដោយផ្អែកលើផែនការអភិវឌ្ឍស្ថាប័នរបស់អង្គភាព និងតម្រូវការចាំបាច់ក្នុងការអនុវត្តកម្មវិធីគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអាស្រ័យលើលទ្ធភាពនៃមូលនិធិជាក់ស្តែងប្រចាំឆ្នាំ។

ការលើកទឹកចិត្តទាំង ៤ ប្រភេទខាងលើនេះ អាចទទួលត្រួតគ្នាបាន។

## ជំពូកទី៣
## យន្តការ នីតិវិធីនិងការត្រួតពិនិត្យ

**ប្រការ៧.-**

ថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមានរដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ រួមទាំងទីប្រឹក្សានិងជំនួយការ ត្រូវទទួលបានការលើកទឹកចិត្តដោយផ្អែកលើសមិទ្ធកម្មការងារតាមការកំណត់និងវាយតម្លៃដោយផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៨.-**

ត្រូវបង្កើតគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្តនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលសរសេរជាអក្សរកាត់ថា **គ.ស.ល** ដែលមានសមាសភាពដូចខាងក្រោម៖

១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធាន

២- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១ ឬច្រើនរូប អនុប្រធាន

៣- អគ្គលេខាធិការគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមាជិក

៤- អគ្គលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក។

សមាសភាពជាក់ស្តែងនៃ **គ.ស.ល** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គ.ស.ល** មានអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការក្នុងការបំពេញមុខងាររបស់ខ្លួន។

**ប្រការ៩.-**

**គ.ស.ល** មានមុខងារនិងភារកិច្ច ដូចខាងក្រោម៖

- ពិនិត្យនិងអនុម័តលើសេចក្តីព្រាងផែនការលើកទឹកចិត្ត និងផែនការអភិវឌ្ឍស្ថាប័នរបស់គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ពិនិត្យនិងសម្រេចលើការផ្តល់ការលើកទឹកចិត្ត ផ្អែកលើផែនការលើកទឹកចិត្ត និងផែនការអភិវឌ្ឍស្ថាប័នដែលបានអនុម័ត
- ត្រួតពិនិត្យនិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តផែនការលើកទឹកចិត្ត និងផែនការអភិវឌ្ឍស្ថាប័នរបស់គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១០.-**

**គ.ស.ល** ត្រូវកោះប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំ ឬតាមការចាំបាច់។ ប្រធាន **គ.ស.ល** អាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួស និងអាចអញ្ជើញថ្នាក់ដឹកនាំក្រសួង និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋានឱ្យចូលរួមកិច្ចប្រជុំតាមការចាំបាច់។

**ប្រការ១១.-**

ត្រូវបង្កើតគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត នៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋានដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១- អគ្គលេខាធិការ/អគ្គនាយក/អគ្គាធិការ | ប្រធាន |
| ២- អគ្គលេខាធិការរង/អគ្គនាយករង/អគ្គាធិការរង ០១ ឬច្រើនរូប | អនុប្រធាន |
| ៣- ប្រធាននាយកដ្ឋាន ឬ/និងប្រធានលេខាធិការដ្ឋាន | សមាជិក |
| ៤- អនុប្រធាននាយកដ្ឋាន ឬ/និងប្រធានការិយាល័យ | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្តនៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គណៈកម្មាធិការនេះត្រូវមានលេខាធិការដ្ឋាន ឬអង្គភាពប្រហាក់ប្រហែលជាសេនាធិការក្នុងការបំពេញមុខងាររបស់ខ្លួន។

**ប្រការ១២.-**

គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្ត នៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋានមានមុខងារនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំសេចក្តីព្រាងផែនការលើកទឹកចិត្ត ដើម្បីដាក់ជូន **គ.ស.ល** ពិនិត្យ និងអនុម័ត
- ពិនិត្យសម្រេច និងអនុវត្តផែនការផ្តល់ការលើកទឹកចិត្តនៃអង្គភាពរបស់ខ្លួន
- ត្រួតពិនិត្យនិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តផែនការលើកទឹកចិត្តនៃអង្គភាពរបស់ខ្លួន។

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋានអាចបង្កើតក្រុមការងារវាយតម្លៃសមិទ្ធកម្ម និងផ្តល់ការលើកទឹកចិត្តនៅតាមនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្នុងករណីចាំបាច់។

**ប្រការ១៣.-**

គណៈកម្មាធិការវាយតម្លៃ សមិទ្ធកម្មនិងផ្តល់ការលើកទឹកចិត្តនៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន ត្រូវកោះប្រជុំប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ ឬតាមការចាំបាច់។ ប្រធានគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្តល់ការលើកទឹកចិត្តនៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋានអាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំកិច្ចប្រជុំជំនួស និងអាចអញ្ជើញប្រធានគម្រោង ឬ/និងប្រធានក្រុមការងារផ្សេងៗ ឱ្យចូលរួមកិច្ចប្រជុំតាមការចាំបាច់។

**ប្រការ១៤.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនីមួយៗ ត្រូវរៀបចំផែនការលើកទឹកចិត្តប្រចាំឆ្នាំ ដែលត្រូវមាន៖

- ផែនការសកម្មភាពសម្រាប់ផ្តល់ការលើកទឹកចិត្តរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការ-ដ្ឋាន និងអង្គភាពនីមួយៗ ក្នុងការអនុវត្តកម្មវិធី និងគោលនយោបាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គម្រោងថវិកាសម្រាប់អនុវត្តផែនការផ្តល់ការលើកទឹកចិត្ត ដែលត្រូវកំណត់ទៅតាមប្រភេទនៃការលើកទឹកចិត្តនីមួយៗ
- បញ្ជីឈ្មោះមន្ត្រីដែលត្រូវទទួលប្រាក់ឧបត្ថម្ភ ឬ/និងប្រាក់រង្វាន់ទៅតាមគម្រោង ឬ/និងក្រុមការងារ។

**ប្រការ១៥.-**

ផែនការលើកទឹកចិត្ត ត្រូវពិនិត្យនិងអនុម័តបឋមដោយគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្តល់ការលើកទឹកចិត្តរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនីមួយៗ ត្រឹមដំណាច់ខែមីនានៃឆ្នាំនីមួយៗ ដើម្បីបញ្ជូនមក **គ.ស.ល** ពិនិត្យនិងអនុម័តចុងក្រោយ។

ផែនការលើកទឹកចិត្ត ត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍អនុវត្តនៃឆ្នាំចុងក្រោយ។

ផែនការលើកទឹកចិត្ត ដែលត្រូវបានអនុម័តដោយ **គ.ស.ល** ត្រូវបញ្ជូនទៅសាមីអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពដើម្បីអនុវត្ត។

ផែនការលើកទឹកចិត្ត ត្រូវទទួលការត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពប្រចាំខែ ប្រចាំត្រីមាស និងនៅរៀងរាល់ពេលបញ្ចប់គម្រោង ឬក្រុមការងារ ដោយគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្តល់ការលើកទឹកចិត្ត នៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន ហើយត្រូវធ្វើរបាយការណ៍ តាមប្រភេទនីមួយៗ ជូន **គ.ស.ល** ជាទៀងទាត់ ទៅតាមសណ្ឋាប្រតិទិននីមួយៗ។

គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្តល់ការលើកទឹកចិត្ត នៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន មានសិទ្ធិលុបឈ្មោះមន្ត្រីចេញពីបញ្ជីទទួលការលើកទឹកចិត្ត និងផ្លាស់ប្តូរមន្ត្រីបម្រើការងារតាមគម្រោង ឬក្រុមការងារនៅក្នុងឆ្នាំបាន តាមរយៈកិច្ចប្រជុំអនុម័ត និងដោយចេញសេចក្តីសម្រេចរបស់គណៈកម្មាធិការ ហើយត្រូវរាយការណ៍ជូន **គ.ស.ល** ភ្លាមក្រោយពីការសម្រេច។

**ប្រការ១៦.-**

អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវអនុវត្តសវនកម្មប្រចាំឆ្នាំ ដើម្បីត្រួតពិនិត្យអំពីសមិទ្ធកម្មនៃផែនការលើកទឹកចិត្ត ហើយរាយការណ៍ ឬផ្តល់អនុសាសន៍សវនកម្មជូន **គ.ស.ល** ពិនិត្យនិងចាត់វិធានការក្នុងករណីចាំបាច់។

## ជំពូកទី៤

## អន្តរប្បញ្ញត្តិ

**ប្រការ១៧.-**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមអនុវត្តតាមគោលការណ៍ នីតិវិធី យន្តការនិងការត្រួតពិនិត្យការផ្តល់ការលើកទឹកចិត្តដែលមានចែងនៅក្នុងប្រកាសនេះចាប់ពីខែកក្កដា ឆ្នាំ២០១៤ តទៅ។

គ្រប់អង្គភាពលើកលែងតែអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ត្រូវរៀបចំផែនការផ្តល់ការលើកទឹកចិត្តសម្រាប់ ៦ខែ គឺពីខែកក្កដា ដល់ ខែធ្នូ ឆ្នាំ២០១៤ មក **គ.ស.ល** សម្រាប់ការផ្តល់ប្រាក់ឧបត្ថម្ភជីវភាព និងប្រាក់ឧបត្ថម្ភមុខងារ។

ការរៀបចំផែនការលើកទឹកចិត្តប្រចាំឆ្នាំ ត្រូវចាប់ផ្តើមអនុវត្តចាប់ពីឆ្នាំ២០១៥ ជាមួយនឹងការអនុវត្តថវិកាកម្មវិធីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើការកែសម្រួលការបែងចែកប្រាក់រង្វាន់របស់ខ្លួនទៅតាមគោលការណ៍ នីតិវិធី យន្តការ និងការត្រួតពិនិត្យការផ្តល់ការលើកទឹកចិត្តដែលមានចែងនៅក្នុងប្រកាសនេះ តាមរយៈការស្នើសុំកែសម្រួលលើប្រកាស និងសេចក្តីណែនាំពាក់ព័ន្ធជាធរមាន ហើយចាប់ផ្តើមអនុវត្តពីខែកក្កដា ឆ្នាំ២០១៤ តទៅ ដោយអនុញ្ញាត

ឱ្យកំណត់សន្ទស្សន៍ និងតម្លៃឯកតានៃសន្ទស្សន៍ដោយខ្លួនឯង និងដោយផ្អែកលើប្រាក់រង្វាន់របស់ខ្លួនដែលបានកំណត់។

តម្លៃឯកតានៃសន្ទស្សន៍សម្រាប់ឆ្នាំ២០១៤ នេះ ត្រូវបានកំណត់ស្មើនឹង ៣ ៨០០ (បីពាន់ប្រាំបីរយ) រៀល ។ តម្លៃឯកតានៃសន្ទស្សន៍នេះនឹងត្រូវកំណត់ឡើងវិញរៀងរាល់ឆ្នាំ និងតាមការចាំបាច់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៩.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ ១៩
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៥២៣.....សហវ.ប្រក

**ប្រកាស**
**ស្តីពី**
**វិធាននិងនីតិវិធីចាត់ទុកបំណុលពន្ធមិនអាចប្រមូលបាន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CABOMDIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣១ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីក្ស័យធន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់វិធាននិងនីតិវិធីចាត់ទុកបំណុលពន្ធមិនអាចប្រមូលបាន ដោយអនុលោមតាមចំណុច៤(ខ) មាត្រា១០៧ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ២.- គោលបំណង**

ប្រកាសនេះមានគោលបំណង ដូចខាងក្រោម÷

- ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រមូលបំណុលពន្ធ
- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការតឹងទារបំណុលពន្ធ ដើម្បីទប់ស្កាត់អំពើគេចវេសពន្ធ
- កំណត់ និងបែងចែកឱ្យបានច្បាស់លាស់រវាងបំណុលពន្ធដែលអាចប្រមូលបាន និងបំណុលពន្ធមិនអាចប្រមូលបាន
- ផ្តល់ភាពអនុគ្រោះដល់អ្នកជាប់ពន្ធ ដែលពុំមានលទ្ធភាពពិតប្រាកដក្នុងការទូទាត់បំណុលពន្ធ
- ពង្រឹងវប្បធម៌នៃការបង់ពន្ធ។

**ប្រការ៣.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធគ្រប់ប្រភេទ ទោះជារូបវន្តបុគ្គលក្តី ឬនីតិបុគ្គលក្តី ដែលពុំមានលទ្ធភាពពិតប្រាកដក្នុងការទូទាត់បំណុលពន្ធ។

**ប្រការ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ បច្ចេកស័ព្ទត្រូវបានកំណត់និយមន័យ ដូចតទៅ÷

- "**បំណុលពន្ធ**" សំដៅដល់ប្រាក់ពន្ធនិងអាករគ្រប់ប្រភេទ ដែលអ្នកជាប់ពន្ធមិនបានបង់ នៅពេលដល់កំណត់ត្រូវបង់ រួមទាំងប្រាក់ពន្ធបន្ថែម ការប្រាក់ និងប្រាក់ពិន័យគ្រប់ប្រភេទពាក់ព័ន្ធនឹងអំពើបំពានកាតព្វកិច្ចពន្ធដារ។

- "**ប្រធានស័ក្តិ**" សំដៅដល់បាតុភូត ឬព្រឹត្តិការណ៍ដែលកើតឡើងដោយមិនអាចព្យាករណ៍ទុកជាមុន មិនអាចជំនះបាន និងស្ថិតនៅក្រៅឆន្ទៈរបស់អ្នកជាប់ពន្ធ ដែលមានជាអាទិ៍ គ្រោះធម្មជាតិដែលរួមមាន ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី, សង្គ្រាម កុប្បកម្ម ឬគ្រោះមហន្តរាយជាយថាហេតុ។
- "**បំណុលពន្ធមិនអាចប្រមូលបាន**" សំដៅដល់បំណុលពន្ធទាំងឡាយណាដែលអ្នកជាប់ពន្ធបានជំពាក់ ហើយពុំមានលទ្ធភាពពិតប្រាកដក្នុងការទូទាត់សង ក្នុងរយៈពេលបីឆ្នាំយ៉ាងតិច គិតចាប់ពីកាលបរិច្ឆេទកត់ត្រាជាបំណុលពន្ធ និងត្រូវបានទទួលស្គាល់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៥.- លក្ខណវិនិច្ឆ័យ**

បំណុលពន្ធ អាចត្រូវបានចាត់ទុកជាបំណុលពន្ធមិនអាចប្រមូលបាន លុះត្រាតែបំពេញលក្ខណវិនិច្ឆ័យត្រួតគ្នាទាំងបី ដូចខាងក្រោម÷

១- បំណុលពន្ធ មានអាយុកាលយ៉ាងតិចបីឆ្នាំ គិតចាប់ពីកាលបរិច្ឆេទកត់ត្រាបំណុលពន្ធ

២- អ្នកជាប់ពន្ធ មានអសារធនភាព ឬគ្មានទ្រព្យសម្បត្តិសម្រាប់ទូទាត់បំណុលពន្ធ

៣- អ្នកជាប់ពន្ធ មានស្ថានភាពយ៉ាងតិចមួយក្នុងចំណោមស្ថានភាពខាងក្រោម÷

- បានទទួលមរណភាព ដែលមានលិខិតបញ្ជាក់ពីមន្ត្រីអត្រានុកូលដ្ឋាន
- ក្លាយជាជនពិការ ចាស់ជរា ឬជាប់ពន្ធនាគារ ដែលមិនអាចធ្វើការ និងមិនអាចរកចំណូលបាន
- បានបាត់ខ្លួន ដែលត្រូវបានប្រកាសដោយសេចក្តីសម្រេចរបស់តុលាការ
- ក្ស័យធន ដែលត្រូវបានប្រកាសដោយសេចក្តីសម្រេចរបស់តុលាការ
- មានប្រាក់ចំណូលស្ទើរតែមិនគ្រប់គ្រាន់សម្រាប់ទូទាត់ចំណាយរស់នៅជាមូលដ្ឋាន ដោយមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច និងមានរបាយការណ៍ចុះត្រួតពិនិត្យរបស់ក្រុមការងារកំណត់បំណុលពន្ធមិនអាចប្រមូលបាន
- ទទួលរងគ្រោះដោយប្រធានស័ក្តិ ដែលមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច និងមានរបាយការណ៍ចុះត្រួតពិនិត្យរបស់ក្រុមការងារកំណត់បំណុលពន្ធមិនអាចប្រមូលបាន។

**ប្រការ៦.- អានុភាព**

ការចាត់ទុកជាបំណុលពន្ធមិនអាចប្រមូលបាន មានអានុភាពធ្វើឱ្យបំណុលពន្ធ រួចផុតពីការអនុវត្តប្រាក់ពន្ធបន្ថែម ការប្រាក់ និងការពិន័យផ្សេងៗ ដែលអាចកើតមានឡើង នៅក្រោយពេលប្រកាសចាត់ទុកជាបំណុលពន្ធមិនអាចប្រមូលបាន។

ការចាត់ទុកជាបំណុលពន្ធមិនអាចប្រមូលបាន ពុំមានអានុភាពលុបចោលបំណុលពន្ធរបស់អ្នកជាប់ពន្ធឡើយ។

បំណុលពន្ធមិនអាចប្រមូលបាន ត្រូវកត់ត្រាក្នុងបញ្ជីមួយដោយឡែក និងត្រូវធ្វើជាកម្មវត្ថុនៃការតាមដានដោយអង្គភាពពន្ធដារពាក់ព័ន្ធ។

ការទារបំណុលពន្ធ អាចអនុវត្តបានគ្រប់ពេលវេលា នៅពេលដែលអ្នកជាប់ពន្ធមានសារធនភាព និងបំណុលពន្ធស្ថិតនៅក្នុងរយៈពេលនៃអាជ្ញាយុកាល។

**ប្រការ៧.- សមាសភាពក្រុមការងារកំណត់បំណុលពន្ធមិនអាចប្រមូលបាន**

ត្រូវបានបង្កើតក្រុមការងារកំណត់បំណុលពន្ធមិនអាចប្រមូលបាន ដែលមានសមាសភាព ដូចខាងក្រោម÷

១-អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ ០១ រូប ប្រធាន

២-ប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធនិងបំណុលពន្ធ អនុប្រធាន

៣-ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ សមាជិក

៤-ប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ សមាជិក

៥-ប្រធានការិយាល័យបំណុលពន្ធ នៃនាយកដ្ឋានសេវាអ្នកជាប់ពន្ធនិងបំណុលពន្ធ លេខាធិការ។

សមាសភាពជាក់ស្តែង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៨.- ភារកិច្ចក្រុមការងារកំណត់បំណុលពន្ធមិនអាចប្រមូលបាន**

ក្រុមការងារកំណត់បំណុលពន្ធមិនអាចប្រមូលបាន មានភារកិច្ច ដូចខាងក្រោម÷

- ពិនិត្យនិងផ្ទៀងផ្ទាត់អំពីបំណុលពន្ធ របស់អ្នកជាប់ពន្ធទាំងឡាយ ដោយផ្អែកលើលក្ខណវិនិច្ឆ័យ នៃបំណុលពន្ធមិនអាចប្រមូលបាន
- ចុះត្រួតពិនិត្យដល់ទីតាំងគ្រឹះស្ថានអាជីវកម្ម ឬកន្លែងស្នាក់នៅរបស់អ្នកជាប់ពន្ធ
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការចុះត្រួតពិនិត្យ និងលើកសំណើជូនអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យនិងសម្រេច ឬស្នើសុំការសម្រេច លើការចាត់ទុកបំណុលពន្ធជាបំណុលពន្ធមិនអាចប្រមូលបាន។

**ប្រការ៩.- សិទ្ធិសម្រេច**

សិទ្ធិសម្រេចចាត់ទុកបំណុលពន្ធជាបំណុលពន្ធមិនអាចប្រមូលបាន គឺជាសមត្ថកិច្ចរបស់÷

១-អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ចំពោះបំណុលពន្ធនីមួយៗ ដែលមានទឹកប្រាក់តិចជាង ឬស្មើនឹង ៥០០.០០០.០០០(ប្រាំរយលាន) រៀល ដោយផ្អែកលើសំណើរបស់ក្រុមការងារកំណត់បំណុលពន្ធមិនអាចប្រមូលបាន។

២-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះបំណុលពន្ធនីមួយៗ ដែលមានទឹកប្រាក់លើសពី ៥០០.០០០.០០០ (ប្រាំរយលាន) រៀល ដោយផ្អែកលើសំណើរបស់អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។

**ប្រការ១០.- កិច្ចដំណើរការ**

ក្រុមការងារកំណត់បំណុលពន្ធមិនអាចប្រមូលបាន ត្រូវរៀបចំពិនិត្យនិងផ្ទៀងផ្ទាត់បំណុលពន្ធទាំងអស់ ដែលមានអាយុកាលលើសពីបីឆ្នាំ និងរៀបចំសំណើអំពីការចាត់ទុកបំណុលពន្ធ ជាបំណុលពន្ធមិនអាចប្រមូលបាន ជូនអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីពិនិត្យនិងសម្រេច។

ក្នុងករណីដែលបំណុលពន្ធលើសពីដែនសមត្ថកិច្ចរបស់ខ្លួន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវស្នើសុំការសម្រេច ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អគ្គនាយកដ្ឋានពន្ធដារ ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំ អំពីបំណុលពន្ធមិនអាចប្រមូលបាន ដែលត្រូវបានសម្រេច ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ១១._ និរាករណ៍**

ប្រកាសលេខ ១៩៣ សហវ.អពដ.ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីវិធាននិងនីតិវិធីចាត់ទុកបំណុលពន្ធជាប្រាក់ពន្ធមិនអាចប្រមូលបាន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២._ ការអនុវត្តប្រកាស**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ២៥៣ ឧសក.ពគ.ប្រក.

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ៥៤៣/១៤ គ.វ.ក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ម្យូហ្ស ហ្គាម៉ិន (ខេមបូឌា) ហ្វេកធើរី ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៣

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ម្យូហ្ស ហ្គាម៉ិន (ខេមបូឌា) ហ្វេកធើរី (MUSE GARMENT (CAMBODIA) FACTORY LTD.) តំណាងដោយ លោក KAM WING FUNG RAYMOND សញ្ជាតិចិន (ហុងកុង) អាយុ៣៧ឆ្នាំ កាន់លិខិតឆ្លងដែនលេខ K03769566 ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣ មានអាសយដ្ឋានបច្ចុប្បន្ន៖ Unit 2101, 21/F West ley Square, 48 Hoi Yuen Road, Kwun Tong, Kow Loon, Hong Kong. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញាដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ផ្លាកឈ្មោះរោងចក្រ ៖** *"រោងចក្រកាត់ដេរសម្លៀកបំពាក់ ម្យូហ្ស ហ្គាម៉ិន (ខេមបូឌា) ហ្វេកធើរី"*

**ទីតាំងរោងចក្រ ៖** *"ភូមិបាគូ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញ បច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្ដល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញ លក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្ដល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្ដល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្ដាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្ដល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្ដាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្ដល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្ដីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ: ២៥៤ ឧស្ស.កន.ប្រក

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ៥៧៥ អនក្រ/បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-យោងលិខិតលេខ២៨៦៦/១៣គ.វ.ក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស្មាត ភី ហ្គាមេន ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៣

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ស្មាត ភី ហ្គាមេន (SMART PEA GARMENT LTD.) តំណាងដោយលោកស្រី KOK PEI FOONG សញ្ជាតិសិង្ហបុរី អាយុ៣៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ E3875735L ចុះថ្ងៃទី០៩ ខែ០៥ ឆ្នាំ២០១៣ មានអាសយដ្ឋានបច្ចុប្បន្ន៖ #136B Hillview Avenue #07-03 S(669607) Singapore. ធ្វើការបង្កើតសាខារោងចក្រ ស្មីមុនសញ្ញា ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ . ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh Phone : 855-23-211141 Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ ស្មាត ភី ហ្គាមេន សាខាទី១ "*
**ទីតាំងរោងចក្រ ៖** *" ផ្លូវNorth-Bridge ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជន ងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្ម ប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្ម រោងចក្រប្រចាំ ០៣ ឆ្នាំ ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន ។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មី នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧ ។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់អោក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រនឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីវត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ។ ប្រកាសនេះ អាចដកហូតស្របតាម មាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលារាជធានីភ្នំពេញ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៣០៥៧ ឧស គ.ន.ប្រក.

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
-យោងលិខិតលេខ៥៨៣/១៤គ.វ.ក ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន សេឌូណូ ខេមបូ នីតធីង ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន សេឌូណូ ខេមបូ នីតធីង (SEDUNO CAMBO KNITTING CO., LTD.) តំណាងដោយ លោក WU ZHONGBAO សញ្ជាតិចិន អាយុ៥១ឆ្នាំ កាន់លិខិតឆ្លងដែនលេខG52159781 ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១១ មានអាសយដ្ឋានបច្ចុប្បន្ន៖ Guxi Road, Gulin Zhen, Yinzhou, Ningbo, China. ធ្វើការបង្កើតរោងចក្រ ផលិតឧស្សាហកម្ម ដូចខាងក្រោម៖

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code** |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ សេខូល្វា ខេមបូ នីតធីង "*
**ទីតាំងរោងចក្រ៖** *" ភូមិកណ្តឹងតូច ឃុំកណ្តឹង ស្រុកបាទី ខេត្តតាកែវ "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។ ៕

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៨៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំរំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តតាកែវ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះ តាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០១៤

**ជ. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**<u>ចម្លងជូន៖</u>**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលាខេត្តតាកែវ

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ៣៣.៤.៣..ឧសក..កកន.ប្រក.

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

-យោងលិខិតលេខ ២៥៩៦/១៣គ.វ.ក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ហេង ស្តូរៀ ថេកស្តាយ ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ហេង ស្តូរៀ ថេកស្តាយ (HENG STORIA TEXTILE Co., Ltd.) តំណាងដោយ លោក ហេង បូលីណា សញ្ជាតិខ្មែរ អាយុ៣៩ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០១៧៥៥៦៤ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១ មានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ៣០ ផ្លូវ១៩៦ ក្រុម៣៧ សង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *" រោងចក្រកាត់ដេរសម្លៀកបំពាក់ ហេង ស្មៀ ថេកស្ទាយ "*
**ទីតាំងរោងចក្រ៖** *" ក្រុមទី៨ ភូមិ៩១ សង្កាត់ច្រាំងចំរេះទី២ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ "*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។
-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។
-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។
-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណាដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។ /.

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់ៗ

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៩៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០១៤

**ជ. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-សាលារាជធានីភ្នំពេញ

"ដើម្បីជូនព្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ